ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

ក

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០២-០១-១៩៩៦- ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៦/០១ ប្រទានងារ **សម្ដេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ** នៃ កម្ពុជា ១

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០៣-០១-១៩៩៦ -អនុក្រឹត្យលេខ ០១ អនក្រ.បក ស្ដីពីបទបញ្ជាផ្ទៃក្នុង នៃ ក្រុមប្រឹក្សាភិបាលអាជ្ញាធរ «អប្សរា» ២

០៥-០១-១៩៩៦- អនុក្រឹត្យលេខ ០២ អនក្រ.បក ស្ដីពីការកែសំរួលទំហំដី តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ ៦

០១-០១-១៩៩៦- អនុក្រឹត្យលេខ ០១ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ ៨

០២-០១-១៩៩៦- អនុក្រឹត្យលេខ ០២ អនក្រ.តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ ៩

០២-០១-១៩៩៦- អនុក្រឹត្យលេខ ០៣ អនក្រ .តត ស្ដីពីការផ្ដល់មេដាយ ស្ថាបនាជាតិ ១១

០៥-០១-១៩៩៦- អនុក្រឹត្យលេខ ០៤ អនក្រ. តត ស្តីពីការតម្លើង
ឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ ១២
០៥-០១-១៩៩៦- អនុក្រឹត្យលេខ ០៥ អនក្រ. តត ស្តីពីការតែងតាំង
លោក ថៃ ចំរុងរិទ្ធ ជានាយកខុទ្ទកាល័យ និងទីប្រឹក្សា
ផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ១៣

២ - សារាចរ

០៥-០១-១៩៩៦ -សារាចរលេខ ០១ ស.រ ស្តីពីការឈប់សំរាករបស់មន្ត្រីរាជការ
និយោជិត កម្មករ ក្នុងឱកាសទិវាខួបអនុស្សាវរីយ៍ថ្ងៃ ៧មករា ១៤

III . ការិយាល័យក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៣-០១-១៩៩៦-ប្រកាសលេខ ០០២ ពណគន.ប្រក ប្រគល់ការគ្រប់គ្រង
ឃ្លាំងលេខ ៣ ត.ម៦ ជូនក្រុមហ៊ុន មុន្នី ស៊ីណាមិុច ១៥

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

០៥-០១-១៩៩៦-ប្រកាសលេខ ០២ ផក.ប្រក អនុញ្ញាតអោយលោយសុខឡាត់
ជនជាតិខ្មែរ បើកដំណើរការ រោងជាងផលិតគ្រឿងសង្ហារឹម ១៦
០៥-០១-១៩៩៦-ប្រកាសលេខ ០៣ ផក.ប្រក អនុញ្ញាតអោយលោក ម៉ៅ ហេង
ជនជាតិខ្មែរ បើកដំណើរការផលិតកម្មគ្រឿងសង្ហារឹម ១៧

០៥–០១–១៩៩៦–ប្រកាសលេខ ០៤ ផក. ប្រក អនុញ្ញាតអោយអ្នកស្រី
គួយ សាម៉ឿន ជនជាតិខ្មែរ បើកដំណើរការរោងជាង
ផលិតគ្រឿងសង្ហារឹម ១៨
០៥–០១–១៩៩៦–ប្រកាសលេខ ០៥ ផក. ប្រក អនុញ្ញាតអោយលោកស្រី ឈី ឌើ
ជនជាតិខ្មែរ បន្តដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម ១៩
០៥–០១–១៩៩៦–ប្រកាសលេខ ០៦ ផក. ប្រក អនុញ្ញាតអោយលោកស្រី
ទុំដានី ស្រីដានីឆេង ជនជាតិខ្មែរ បើកដំណើរការឡ
ផលិតនំប៉ុង ២០

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

០៣–០១–១៩៩៦–ប្រកាសលេខ ០០១/៩៦ ពម. ប្រក អនុញ្ញាតជូនលោក
ថៃ ហ៊ាន់ បើកអាជីវកម្មទូរទស្សន៍ខ្សែកាប នៅក្រុងព្រះសីហនុ ២១
០៣–០១–១៩៩៦–ប្រកាសលេខ ០០២/៩៥ ពម. ប្រក អនុញ្ញាតអោយលោក
ខ៊ិត សុឃី បើកអាជីវកម្ម រោងពុម្ពឈ្មោះ «ឥន្ទ្រីមាស» ២២

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

០៤–០១–១៩៩៦–ប្រកាសលេខ ១៤ អយក. ប្រក ស្តីពីការផ្តាច់សាលាបឋមសិក្សា
ពីស្រុកកំពត និងស្រុកកំពង់ត្រាច ខេត្តកំពតអោយស្ថិតនៅ
ក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជននិង កីឡាក្រុងកែប ២៤

៥ - ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

០៤-០១-១៩៩៦-សេចក្តីសំរេចលេខ ០២/៩៦ កធស.នធ ស្តីពីការអនុញ្ញាត អោយបង្កើតសមាគមធម្មិកសង្គហៈ ២៦

០៦-០១-១៩៩៦- សេចក្តីសំរេចលេខ ០៥/៩៦ កធស ស្តីពីការអនុញ្ញាតច្បាប់ អោយបើកព្រះវិហារចិន ព្រះម៉ែចារា រាជធានីភ្នំពេញ ២៧

៦ - រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

០៣-០១-១៩៩៦-សេចក្តីសំរេចលេខ ០៤ សសរ.មស.ក្រខ ស្តីពីការ បែងចែកសិស្ស និស្សិត ចំនួន ២៥៩ នាក់ ដែលទើប បញ្ចប់ការសិក្សាក្នុង និងក្រៅប្រទេស ២៨

៧ - ទីស្តីការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

ប្រកាស

០៦-០១-១៩៩៦-ប្រកាសលេខ ១២ សកអ ស្តីពីថ្ងៃឈប់បុណ្យដែលត្រូវ មានប្រាក់ឈ្នួល ៤៦

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០១៩៦/០១

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ប្រទានងារ

មហេសីយើងជា

សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ

នៃកម្ពុជា

ធ្វើនៅព្រះបរមរាជវាំងយើង រាជធានីភ្នំពេញ
ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ០១ អនក្រ.បក

ស្តីពីចនបញ្ជាផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាលអាជ្ញាធរ « អប្សរា »

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការ រៀបចំតំបន់ និង ការគ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និង រៀបចំតំបន់អង្គរ (អាជ្ញាធរ អប្សរា)
- តាមសំណើរបស់អគ្គនាយកអាជ្ញាធរ « អប្សរា »

សំរេច

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : សមាសភាពនៃក្រុមប្រឹក្សាភិបាល សមាសភាពនៃប្រធាន និង អនុប្រធានដែលបានបញ្ជាក់ក្នុងមាត្រា ទី៥ នៃព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរ « អប្សារា » ។

មាត្រា ២ : ប្រភេទនៃការពិភាក្សាសំរេច ដែលបានបញ្ជាក់នៅក្នុងមាត្រាទី ៦ នៃ ព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ « អប្សារា » ។

មាត្រា ៣ : ចំនួនសម័យប្រជុំប្រចាំឆ្នាំ របៀបបែបបទ នៃការធ្វើសេចក្តីសំរេចដូចដែលមានចែងក្នុងមាត្រា ៧ នៃព្រះរាជក្រឹត្យ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ «អប្សារា» ។

ជំពូកទី ២

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាល

មាត្រា ៤ : លេខាធិការដ្ឋានផ្នែករដ្ឋបាលនៃក្រុមប្រឹក្សាភិបាលត្រូវទទួលបន្ទុកដោយភ្នាក់ងារម្នាក់នៃរាជអាជ្ញាធរ «អប្សារា» តាមបញ្ជាអនុប្រធានដែលមានការព្រមព្រៀងពីអគ្គនាយក ។

មាត្រា ៥ : ការិយាល័យនៃក្រុមប្រឹក្សាភិបាល មានសមាសភាពដូចតទៅ ៖

- ទេសរដ្ឋមន្ត្រីទទួលបន្ទុក វប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ជាប្រធាន
- អនុប្រធាន ២ នាក់
- អភិបាលខេត្តសៀមរាប ឬ តំណាង
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង

ការិយាល័យត្រៀមរៀបចំសេចក្តីសំរេចនានារបស់ក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាល អាចវិភែកអំណាចខ្លះ ក្នុងការធ្វើសេចក្តីសំរេចអោយទៅការិយាល័យជា

អាទិ៍គឺ ការងារសំខាន់ៗផ្នែក ហិរញ្ញវត្ថុ ការជ្រើសរើសបុគ្គលិកសំខាន់ៗព្រមទាំងតាមដានអោយបានទៀងទាត់នូវសកម្មភាពរបស់អាជ្ញាធរ « អប្សារា » ។

អគ្គនាយកដោយមានជំនួយការពីនាយកហិរញ្ញវត្ថុផង រៀបចំព្រមទាំងដាក់ជូននូវសំណុំរឿងផ្សេងៗ អោយការិយាល័យពិនិត្យ ។ ស្នងការគណនីរួមប្រជុំការិយាល័យរាល់ពេលណាដែលត្រូវការ ។

មាត្រា ៦ : ចំណាយក្នុងដំណើរការនៃក្រុមប្រឹក្សាភិបាល ត្រូវរ៉ាប់រងតាមឥណទានដែលបើកឡើងជារៀងរាល់ឆ្នាំក្នុងថវិកាអាជ្ញាធរ « អប្សារា » ។

ជំពូកទី ៣

ការដំណើរការ

មាត្រា ៧ : របៀបវារៈត្រូវបញ្ជូនទៅអោយសមាជិកទាំងអស់ យ៉ាងហោចណាស់ក៏១០ថ្ងៃមុនដែរ។

មាត្រា ៨ : ពេលមានប្រជុំក្រុមប្រឹក្សាភិបាល សមាជិកដែលមានវត្តមានត្រូវចុះហត្ថលេខានៅលើបញ្ជីវត្តមាន ។ កាលបើសមាជិកណាមួយអកខានពុំបានចូលរួមក្នុងអង្គប្រជុំ តែបានប្រគល់អំណាចអោយទៅសហសេវិកម្នាក់របស់ខ្លួន សិទ្ធិអំណាចនោះត្រូវភ្ជាប់ទៅជាមួយនឹងបញ្ជីវត្តមានផង ។

មាត្រា ៩ : ប្រឹក្សាភិបាលអាចបើកសម័យប្រជុំឡើងបានលុះត្រាតែ ២/៣ នៃចំនួនសមាជិកបានមករួមប្រជុំ ឬ ប្រគល់អំណាចអោយសហសេវិកម្នាក់ទៀត ។

មាត្រា១០ : ក្រុមប្រឹក្សាភិបាលអាចប្រគល់អំណាចទាំងស្រុង ឬ មួយភាគក្នុងការសំរេចផ្សេងៗទៅដល់អគ្គនាយក លើកលែងតែអំណាចទាំងប៉ុន្មានដែលកំណត់នៅមាត្រាទី ៦ នៃព្រះរាជក្រឹត្យ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ « អប្សារា » ។

មាត្រា ១១: ការបោះឆ្នោតធ្វើឡើងដោយលើកដៃ ។ ក្នុងករណីដែលចំនួនអ្នកមកប្រជុំ ឬ អ្នកទទួលអំណាចបោះឆ្នោតពុំគ្រប់ ២/៣ នៃសេចក្តីសំរេចដែលចែងនៅក្នុងរបៀបវារៈពេលនោះ អាចយកទៅធ្វើ នៅសម័យប្រជុំលើកក្រោយ បន្ទាប់ពីមានការកោះហៅត្រឹមត្រូវតាមបែបបទ ។ សេចក្តីសំរេចនោះ ត្រូវទទួលសំលេងភាគច្រើនដាច់ខាត នៃសមាជិកដែលមកប្រជុំ ។

មាត្រា១២ : សេចក្តីសំរេចត្រូវអនុម័តឡើង កាលណាបានទទួលសំលេងភាគច្រើនដាច់ខាតនៃសមាជិកដែលបានមកប្រជុំ ឬ ដែលបានប្រគល់អំណាចបោះឆ្នោតដល់សមាជិកម្នាក់ទៀត ។ សេចក្តីសំរេចទាំងប៉ុន្មានអាចធ្វើទៅបានលុះត្រាតែយ៉ាងហោចណាស់ ២/៣ នៃសមាជិកបានចូលរួម ឬ បានប្រគល់អំណាចបោះឆ្នោត ។

មាត្រា១៣ : កំណត់ហេតុនៃសម័យប្រជុំនីមួយៗ ត្រូវធ្វើឡើងដោយលេខាធិការដ្ឋានរដ្ឋបាលក្រោមនិវាទ នៃ សហប្រធានទាំង ២ ឬ ក្រោមនិវាទអនុប្រធានដែលបានទទួលអំណាចពីសហប្រធាន ។ កំណត់ហេតុនោះមានចុះឈ្មោះសមាជិកដែលមានវត្តមាន ឬ ដែលបានប្រគល់អំណាចតំណាងបុគ្គល ដទៃ ដែលមកចូលរួមក្នុងសម័យប្រជុំព្រម ទាំងសេចក្តីសំរេចដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល ។ កំណត់ហេតុត្រូវផ្សព្វផ្សាយទៅដល់រាល់សមាជិកនៃក្រុមប្រឹក្សាភិបាល ព្រមទាំងបុគ្គលដទៃដែលមានវត្តមាននៅអង្គប្រជុំដែលពោលខាងលើ យ៉ាងហោចណាស់ ១០ ថ្ងៃ មុនសម័យប្រជុំបន្ទាប់ ។

កំណត់ហេតុទាំងឡាយ ត្រូវទទួលសេចក្តីយល់ព្រម នៅពេលផ្តើមសម័យប្រជុំបន្ទាប់ ។

ឯកសារចំលង ឬ ឯកសារដកស្រង់នៃកំណត់ហេតុដែលត្រូវបញ្ជូលចំពោះមុខអាជ្ញាធរតុលាការ ត្រូវប្រធានចុះហត្ថលេខា ទោះជាប្រធានបានរួមចំណែក ឬ មិនបានរួមចំណែកក្នុងការពិភាក្សា សំរេចក៏ដោយ ។

មាត្រា១៤ : សមាជិកទាំងឡាយនៃក្រុមប្រឹក្សាភិបាលពុំអាចរក ឬ រក្សាទុកនូវផលប្រយោជន៍ណាមួយ ពុំអាចទទួលមុខងារណាមួយនៅក្នុងសហគ្រាសទាំងឡាយណាដែលទទួលការងារអំពីអាជ្ញាធរ «អំប្បារា» ក្នុងការសាងសង់ក្តី ក្នុងការផ្តល់ភស្តុភារក្តី ។ ម្យ៉ាងវិញទៀតសមាជិកទាំងនោះក៏ពុំអាចទទួល ជាកំរៃអ្វីមួយប្រសិនបើខ្លួនបានបំរើការដោយប្រការណាក្តីចំពោះសហគ្រាសនោះ ។

ជំពូកទី ៤

អវសានបញ្ញត្តិ

មាត្រា ១៥ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦ : អាជ្ញាធរ « អប្សារា » មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ០២ អនក្រ.បក

ស្តីពីការកែសម្រួលទំហំដី តំបន់ឧស្សាហកម្មស្ទឹងហាវ

ក្រុងព្រះសីហនុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម

សំរេច

មាត្រា ១ : មាត្រា ៤ នៃអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត តំបន់ឧស្សាហកម្មស្ទឹ...ាវ ក្រុងព្រះសីហនុ ត្រូវបានកែសំរួលដូចតទៅ ÷

១–តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ មានទំហំប្រមាណ ១.១០០ ហិកតា មានទីតាំងដូច បានបញ្ជាក់តាមផែនទីដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ និង ដែលស្ថិតនៅក្នុងចន្លោះ :

ចាប់ពី

ខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣២,៨

និងខ្សែរយៈទទឹង ១០° ៤២,៣ ខ្សែរយៈបណ្តោយ ១០៣° ៣២,៩

ទៅដល់

ខ្សែរយៈទទឹង ១០° ៤៤,១ ខ្សែរយៈបណ្តោយ ១០៣° ៣៧,២

និងខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣៧,៤

អាងទឹកសាបដែលមានសញ្ញាបញ្ជាក់ក្នុងផែនទីដែលភ្ជាប់នឹងអនុក្រឹត្យនេះ ជាប្រភពទឹក សាបសំរាប់បំរើសេចក្តីត្រូវការរបស់តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ ។

២–តំបន់រោងចក្រចំរាញ់ប្រេងកាត ឃ្លាំងស្តុកប្រេងឥន្ធនៈ និង បុរីកម្មករ នៅស្ទឹងហាវ ក្រុងព្រះ សីហនុ មានទំហំប្រមាណ ៥០ ហិកតា មានទីតាំងនៅជាប់តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះ សីហនុ ដូចបានបញ្ជាក់ក្នុងផែនទី ដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ផែនទី

តំបន់ឧស្សាហកម្ម ស្ទឹងហាវ - ក្រុងព្រះសីហនុ

តំបន់ឧស្សាហកម្មទូទៅ ≈១១០០ ហិកតា



កំណត់សំគាល់

- (ឆ) អាងទឹកសាប
- - - - - - ខណ្ឌសីមានៃតំបន់ឧស្សាហកម្មទូទៅ
- ——— ផ្លូវរថភ្លើង
- (ៃ) រោងចក្រចំរាញ់ប្រេងកាត

0 ៥០០ ១០០០ ១៥០០ ម៉ែ

ព័ន្ធ និង អភិបាលក្រុង ព្រះសីហនុ មានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ០១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះសប្បុរសជនដែលបានបរិច្ចាគថវិកា ជួយកសាងនិងជួសជុលអាគារសិក្សា ព្រមទាំងបំពាក់សំភារៈបរិក្ខារ

បង្រៀនគ្រប់មុខនៅសាលា បឋមសិក្សា ខ្សាម ក្នុងស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម ÷

១-លោកជំទាវ **ម៉ារ្យ ច័ន្ទលាភ** នាមដើម **តាយ៉ាកា យ៉ូហ៊ីកូ** បរិច្ចាគទឹកប្រាក់ ៤១.០០០ ដុល្លារអាមេរិក ។

២-លោកប្រធានអង្គការ«A.A.R»ជប៉ុនបរិច្ចាគទឹកប្រាក់ ១៤.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កំពង់ឆ្នាំង ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ០២ អនក្រ.តត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

– តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជន ជាសមូហភាព និងជាបុគ្គល ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងវិទ្យាល័យមោងឫស្សី និង សាលាបឋមសិក្សាមោង ក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម ÷

ក–មេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១–គណៈកម្មការសមាគមខ្មែរ រស់នៅសហរដ្ឋអាមេរិក–កាណាដា ឧបត្ថម្ភទឹកប្រាក់ ២៥.២២៦ ដុល្លារអាមេរិក ។

ខ–មេដាយស្ថាបនាជាតិថ្នាក់លេខ ២ :

១–ព្រះគ្រូ **ឃឹម ហៀន** គង់នៅទីក្រុងបាងកក ឧបត្ថម្ភទឹកប្រាក់ ៨.៣៣៣ ដុល្លារអាមេរិក ។

គ–មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ :

១–អ្នកស្រី **សុវណ្ណ ចិន** នៅសហរដ្ឋអាមេរិក ឧបត្ថម្ភទឹកប្រាក់ ៣.០០០ ដុល្លារ អាមេរិក ។

២–ព្រះគ្រូ **សោភ គាត់** គង់នៅទីក្រុងបាងកក ឧបត្ថម្ភទឹកប្រាក់ ២.០៨៣ ដុល្លារ អាមេរិក ។

៣–លោក **ថោង ចិន** នៅសហរដ្ឋអាមេរិក ឧបត្ថម្ភទឹកប្រាក់ ២.០៣១ ដុល្លារ អាមេរិក ។

៤–លោក **អ៊ុំ គាន** នៅសហរដ្ឋអាមេរិក ឧបត្ថម្ភទឹកប្រាក់ ២.០០០ ដុល្លារ អាមេរិក ។

៥–លោក **ហ៊ុន ហាន** នៅសហរដ្ឋអាមេរិក ឧបត្ថម្ភទឹកប្រាក់ ១.៤២០ ដុល្លារ អាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខា និងត្រា **ហត្ថលេខា និងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៣ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ ជូនចំពោះលោក JEAN BERNARD BERGER ប្រធានសមាគមទទួលបងប្អូនខ្មែរ នៅប្រទេសបារាំង ដែលបានជួយកសាង ឆ្លងពីអាគារមួយទៅអាគារមួយចំនួន ៣ នៅវិទ្យាល័យព្រះយុគន្ធរ អស់ទឹកប្រាក់ ២.១៤០ ដុល្លារអាមេរិក ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡាត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ — **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខានិងត្រា — **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៤ អនក្រ.តត

ស្តីពីការតំលើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

* * *

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- យោងតាមសំណើ របស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ វរសេនិយឯក ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព លោក **វរសេនិយទោ ហាន ពេជ្រតារា** នាយកសេនាធិការរង កងកាំភ្លើងធំ អគ្គសេនាធិការ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខានិងត្រា **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ០៥ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើចាំបាច់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកអធិការកិច្ច

សំរេច

មាត្រា ១ : តែងតាំងលោក **ថៃ ចំនួនរិទ្ធ** ជានាយកខុទ្ទកាល័យ និង ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិកាកិច្ច ។

មាត្រា ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និង លោក ថៃ ចំនួរិទ្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្ថលេខានិង ត្រា — **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

* * *

២ - សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៩៦

សារាចរលេខ ០១ សរ

ស្តីពីការឈប់សំរាករបស់មន្ត្រីរាជការនិយោជិក កម្មករ ក្នុងឱកាសទិវាខួបអនុស្សាវរីយ៍ ថ្ងៃ ៧ មករា

* * *

ដោយយល់ឃើញថា ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ជាថ្ងៃដែលប្រជារាស្ត្រកម្ពុជា នៅទូទាំងប្រទេស បានរួចចាកផុតពីរបបប្រល័យពូជសាសន៍ រាជរដ្ឋាភិបាលកម្ពុជា កំណត់យកថ្ងៃ ៧ មករា ជារៀងរាល់ឆ្នាំ ជាទិវាបុណ្យ ព្រមទាំងអនុញ្ញាតអោយមន្ត្រី រាជការ និយោជិក កម្មករ ក្នុងព្រះរាជាណាចក្រកម្ពុជា បានឈប់សំរាកការងារចំនួន ១ ថ្ងៃ ក្នុងឱកាសទិវាបុណ្យនេះ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវធ្វើការផ្សព្វផ្សាយ និង អនុវត្តតាមខ្លឹមសារខាងលើអោយមានប្រសិទ្ធភាពខ្ពស់ ។

នាយករដ្ឋមន្ត្រីទី ១ — **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្ថលេខានិង ត្រា — **ហត្ថលេខា និង ត្រា**

នរោត្តម រណឫទ្ធិ — **ហ៊ុន សែន**

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០០២ ពណគន.ប្រក

* * *

រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ កិច្ចសន្យាជួលទីតាំងឃ្លាំងលេខ៣ គ.ម៦ នៃក្រុមហ៊ុនសំភារៈបរិក្ខា ចុះថ្ងៃទី ១៦ ធ្នូ ឆ្នាំ ១៩៩៥ រវាងក្រុមហ៊ុនសំភារៈបរិក្ខារ នៃក្រសួងពាណិជ្ជកម្ម និង ក្រុមហ៊ុន មុន្នី ស៊ីណាម៉ិច តំណាងដោយលោក **សៅ មុន្នីរស្មី**

សំរេច

ប្រការ ១ : ប្រគល់ការគ្រប់គ្រងទីតាំងឃ្លាំងលេខ ៣ គ.ម៦ ក្នុងនោះរួមមាន ដីធ្លី ឃ្លាំងដូចមានចែងក្នុងប្រការ ១ នៃកិច្ចសន្យា ជូនក្រុមហ៊ុន **មុន្នី ស៊ីណាម៉ិច** ។

ប្រការ ២ : ក្រុមហ៊ុន **មុន្នី ស៊ីណាម៉ិច** ត្រូវគោរពនិងអនុវត្តអោយបានល្អ តាមរាល់ប្រការដែលមាន ចែងក្នុងកិច្ចសន្យាចុះថ្ងៃទី ១៦-១២-៩៥ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។.

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមហ៊ុនសំភារៈបរិក្ខារ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះអោយទួលបាន លទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០២ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយលោក **សុខ ឡាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៩៨៣៨ ក.ស្ត ចុះថ្ងៃទី ២២-១០-៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះសង់ថ្មី ផ្លូវលេខ ២៧៨ ក្រុមទី១ ភូមិទួលគោក សង្កាត់ទួលសង្កែ ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាង លើ ។

ប្រការ២ : លោក **សុខ ឡាន់** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម លើទីតាំងដូចបានកំណត់ ក្នុងប្លង់គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្មធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរ មាន ។

ប្រការ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវ័ន្ត ទ្វារ បង្អួច តុ ទូ គ្រែ និងកៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ៥ : ម្ចាស់រោងជាងធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់រោងជាងផ្ញើមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល រាជធានីភ្នំពេញ ។

ប្រការ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៣ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយរោងជាងផលិតគ្រឿងសង្ហារឹម ដែលមានលោក **ម៉ៅ ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០០៩១៩១ ភ.ព ចុះថ្ងៃទី ០៩-១២-៨៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិទីខាងត្បូងឃុំ អណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត បើកដំណើរការផលិតកម្មនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក **ម៉ៅ ហេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះ ត្រូវចាត់ទុកជាមោឃៈ ។

ប្រការ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្មធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរ មាន ។

ប្រការ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវ័ន្ត ទ្វារ បង្អួច ឥដ្ឋការ៉ូ ឈើ តុ ទូ គ្រែ និងកៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែល មានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ៥ : ម្ចាស់រោងជាងធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់រោងជាងផ្ញើមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល ខេត្តកំពត ។

ប្រការ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៤ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី **គុយ សារឿន** ជនជាតិខ្មែរសញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២០០០៤០ ត.ក ចុះថ្ងៃទី ២៣ - ៦ - ៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បើកដំណើរការរោងជាងផលិតកម្ម គ្រឿងសង្ហារឹម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាង លើ ។

ប្រការ២ : អ្នកស្រី **គុយ សារឿន** ត្រូវរៀបចំរោងជាងរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេល៦ខែគិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្មធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

ប្រការ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវ័ន្ត គ្រែ ទ្វារ បង្អួច តុ ទូ រទេះ និងសាឡុង ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម

គឺឈើដែល មានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រង ដោះស្រាយដោយខ្លួនឯង ។

ប្រការ៥ : ម្ចាស់រោងជាងត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពល ខេត្តតាកែវ អំពីកាលបរិច្ឆេទ នៃការចាប់ផ្តើមដំណើរការជាផ្លូវការ និង ធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់រោងជាង ។

ប្រការ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៨៦

ប្រកាសលេខ ០៥ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី ឈី ថៃ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៧២៧៣ ភ.ព ចុះថ្ងៃទី ០៥ - ១២ - ៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១១១ AEO ផ្លូវលេខ ១៥០ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការ រោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុងទីតាំងភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : អ្នកស្រី ឈី ថៃ ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុង ប្រការ១ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពការងារ ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពរាល់ច្បាប់ និងបទបញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ៤ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវ័ន្ត គ្រែ តុ ទូ ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺឈើដែល មានលក្ខណៈស្របច្បាប់ដែលសាមីរោងជាងត្រូវរ៉ាប់រង ដោះស្រាយដោយខ្លួនឯង ។

ប្រការ៥ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ ស្តីពីសកម្មភាពផលិតកម្មប្រចាំខែ របស់រោងជាង ផ្ញើមកក្រសួង តាមរយៈមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល រាជធានីភ្នំពេញ ។

ប្រការ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០៦ ឧក.ប្រក

* * *

ប្រការ១ : អនុញ្ញាតអោយអ្នកស្រី **ទុំ ដានី ស្រីដានីផេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៦៩៦១០ ភ.ព ចុះថ្ងៃទី ១៣ - ៣ - ៩៣ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៩៩ បេ វិថី សម្តេចសីហនុ សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការឡផលិតនំប៉័ង នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខានិងត្រា

ពូ សុធីរៈ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០០១/៩៦ ព.ម.ប្រក

អនុញ្ញាតជូនលោក ថៃ ម៉ាន់ បើកអាជីវកម្មទូរទស្សន៍ ខ្សែកាប

* * *

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យលើសំណើ អនុញ្ញាតច្បាប់បើកអាជីវកម្ម ទូរទស្សន៍ខ្សែកាបរបស់លោក ថៃ-ម៉ាន់ ចុះថ្ងៃទី ២៥ ខែ ១០ ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក ថៃ-ម៉ាន់ បច្ចុប្បន្នស្ថិតនៅផ្ទះលេខ ១ ដេអឺ.០ ផ្លូវលេខ ៧១ សង្កាត់បឹងកេងកង I ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើអាជីវកម្មទូរទស្សន៍ខ្សែកាបសំរាប់បន្តជាវអោយអតិថិជននៅទីក្រុងព្រះសីហនុ ។

